# ការមើលឃើញកម្លាំងរបស់ព្រះអម្ចាស់នៅក្នុងដំណើររឿងរបស់គេឌាន

**សកម្មភាពសិក្សា ទី១ ៖ ការហៅរបស់គេឌាន**

សូមអានពួកចៅហ្វាយ ៦:១៤–១៦,២៣–២៧ ដោយរកមើលការណែនាំរបស់ព្រះអម្ចាស់ទៅកាន់គេឌាន ។ ( វាប្រហែលជាមានប្រយោជន៍ក្នុងការដឹងថា គោឈ្មោល ដែលបានរៀបរាប់នៅក្នុងខទី ២៥–២៦ គឺជានិមិត្តសញ្ញានៃព្រះយេស៊ូវគ្រីស្ទ ។ ព្រះបាល គឺជារូបព្រះក្លែងក្លាយដែលសាសន៍អ៊ីស្រាអែលបានថ្វាយបង្គំ ។ អ្នកតា ជាកន្លែងដែលថ្វាយបង្គំព្រះក្លែងក្លាយ ) ។

- តើគេឌានមានអារម្មណ៍យ៉ាងណាចំពោះអ្វីដែលព្រះអម្ចាស់បានបង្គាប់ឲ្យលោកធ្វើ ?
- តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដើម្បីពង្រឹង និងជួយគេឌាន ?
- តើព្រះអម្ចាស់បានបង្រៀនគេឌាន និងប្រជាជនអ្វីខ្លះជាមួយនឹងការណែនាំរបស់ទ្រង់នៅក្នុង ខទី ២៥–២៧ ?

នៅក្នុងឯកសារនេះ ឬនៅក្នុងកំណត់ហេតុការសិក្សារបស់អ្នក សូមព្រៀងវិធីមួយចំនួនដែលព្រះអម្ចាស់អាចពង្រឹងយើង ។

---

**សកម្មភាពសិក្សា ទី២ ៖ ការកាត់បន្ថយកងទ័ពរបស់គេឌាន**

គេឌានបានក្លាយជាមេដឹកនាំនៃកងទ័ពសាសន៍អ៊ីស្រាអែលចំនួន ៣២,០០០ នាក់ ( សូមមើល ពួកចៅហ្វាយ ៧:៣ ) ។ ពួកម៉ាឌានមានកងទ័ព ១៣៥,០០០ នាក់ ( សូមមើល ពួកចៅហ្វាយ ៨:១០ ) ។ កម្លាំងរបស់សាសន៍អ៊ីស្រាអែលមិនកើតឡើងមកពីការមានចំនួនច្រើននោះទេ ។

សូមអានពួកចៅហ្វាយ ៧:២–៧,ដោយស្វែងរកអ្វីដែលព្រះអម្ចាស់ចង់ឲ្យគេឌានធ្វើជាមួយកងទ័ពរបស់លោក ។

- តើនៅទីបំផុតកងទ័ពគេឌានមានចំនួនប៉ុន្មាន ?
- ហេតុអ្វីបានជាព្រះអម្ចាស់ចង់ឲ្យមានចំនួនតិច ? ( សូមមើល ពួកចៅហ្វាយ ៧:២ ) ។

នៅលើឯកសារនេះ ឬនៅក្នុងសៀវភៅកំណត់ហេតុការសិក្សារបស់អ្នក សូមគូររូបតំណាងមួយចំនួនដែលបង្ហាញពីភាពខុសគ្នានៃទំហំរវាងកងទ័ព សាសន៍ម៉ាឌាន និងកងទ័ព គេឌាន ។

- ប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពរបស់គេឌាន តើអ្នកអាចមានសំណួរអ្វីខ្លះ បន្ទាប់ពីទទួលបានការណែនាំទាំងនេះ ?
- តើសេចក្តីណែនាំទាំងនេះអាចបង្រៀនអ្នកអំពីព្រះអម្ចាស់យ៉ាងដូចម្តេច ?

---

**សកម្មភាពសិក្សា ទី៣ ៖ ការប្រយុទ្ធរវាងកងទ័ពគេឌាន និង ពួកសាសន៍ម៉ាឌាន**

របស់របរដែលបង្ហាញនោះគឺជារបស់របរដែលគេឌានបានណែនាំទាហានរបស់លោកឲ្យយកទៅជាមួយដើម្បីប្រយុទ្ធនឹងកងទ័ពសាសន៍ម៉ាឌាន ។



សូមអាន ពួកចៅហ្វាយ ៧:១៥–១៦ ដើម្បីរករបស់របរទាំងនេះ ។

- តើគេឌានអាចប្រើរបស់របរទាំងនេះក្នុងការប្រយុទ្ធប្រឆាំងនឹងកងទ័ពសាសន៍ម៉ាឌានយ៉ាងដូចម្តេច ?

ព្រះអង្គបានសន្យាដល់គេឌានថាកងទ័ព ៣០០ នាក់នឹងយកឈ្នះកងទ័ពសាសន៍ម៉ាឌាន ( សូមមើល ពួកចៅហ្វាយ ៧:៧ ) ។ សូមអាន ពួកចៅហ្វាយ ៧:១៧–២១,៨:២៨ ដើម្បីស្វែងយល់ពីរបៀបដែលព្រះអម្ចាស់បំពេញការសន្យានេះ ។

នៅក្នុងឯកសារនេះ ឬសៀវភៅកំណត់ហេតុការសិក្សារបស់អ្នក សូមសរសេរសេចក្តីពិតដែលអ្នកបានរៀនពីដំណើររឿងនេះដែលអាចជួយអ្នកនៅពេលអ្នកប្រឈមមុខនឹងឧបសគ្គនានា ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80023177_258_handout_066